# មតកសាសន៍

**១.ការបង្ហាញឆន្ទៈតាមរយៈមតកសាសន៍** ៖ សេរីភាពក្នុងការចាត់ចែងទ្រព្យ ត្រូវបានច្បាប់ទទួលស្គាល់យ៉ាងទូលំទូលាយ ពីពេលរូបវន្តបុគ្គលចាប់កំណើត រហូតទទួលមរណភាព។ សន្តតិកម្មតាមមតកសាសន៍ ជាមធ្យោបាយចាត់ចែងទ្រព្យតាមឆន្ទៈរបស់ម្ចាស់ទ្រព្យមុនពេលស្លាប់ ប៉ុន្តែមតកជនមិនអាចកំណត់អំពីវិធីបែងចែកដែលមានលក្ខណៈប៉ះពាល់ដល់ភាគបម្រុង (សិទ្ធិរបស់សន្តតិជនដែលត្រូវបានច្បាប់ការពារជាអប្បបរមា)។ លើសពីនេះទៅទៀត ការកំណត់ចំណែកមត៌កនេះ ត្រូវតែមានលក្ខណៈសមស្របតាមបទប្បញ្ញត្តិច្បាប់ ផងដែរ ដូចជាការផ្តាច់មត៌កពីសន្តតិជនតាមមតកសាសន៍ ត្រូវបញ្ជាក់មូលហេតុ និងមតកសាសន៍ត្រូវកសាងឡើងតាមបញ្ញត្តិនៃច្បាប់ជាធរមាន(CC#1170)។

**២. បុគ្គលដែលអាចធ្វើមតកសាសន៍** ៖ នីតិជន អនីតិជនដែលទទួលបានអត្តាធីនភាព អនីតិជនដែលរួចផុតពីរបបអាណាព្យាបាលសម្រាប់អនីតិជន ឬអនីតិជនដែលរួចផុតពីអំណាចមេបា អាចធ្វើមតកសាសន៍បាន ដោយនៅពេលធ្វើបណ្តាំ ម្ចាស់បណ្តាំត្រូវមានសមត្ថភាពខាងឆន្ទៈ(CC#1168)លើកលែងតែ មតកសាសន៍ដែលធ្វើឡើងដោយជននៅក្រោមអាណាព្យាបាលទូទៅ ដែលគោរពលក្ខខណ្ឌនៅក្នុងមាត្រា ១១៧៦ នៃក្រមរដ្ឋប្បវេណី។

**៣. ទម្រង់នៃមតកសាសន៍** ៖ មតកសាសន៍ ត្រូវធ្វើឡើងតាមទម្រង់ដែលមានកំណត់នៅក្នុងច្បាប់ ប្រសិនបើមិនគោរពទម្រង់ទេ ត្រូវចាត់ទុកជាមោឃៈ។ ដោយឡែក មតកសាសន៍ដែលមិនបានចុះកាលបរិច្ឆេទ ត្រូវចាត់ទុកថាមានសុពលភាព បើមិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលធ្វើឡើងដោយម្ចាស់បណ្តាំដូចគ្នា។ បើមតកសាសន៍ដែលគ្មានចុះកាលបរិច្ឆេទនោះមានចំនួនច្រើនច្បាប់ និងមតកសាសន៍នោះផ្ទុយគ្នា អានុភាពនៃមតកសាសន៍ទាំងនោះត្រូវកាត់បន្ថយគ្នាទៅវិញទៅមក។ លើសពីនេះទៅទៀត នៅពេលធ្វើមតកសាសន៍ ត្រូវមានសាក្សី ហើយសាក្សីនៃមតកសាសន៍ដែលគ្មានលក្ខណៈសម្បត្តិ មានដូចជា(CC#1172) ៖

-អនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ

-ជនដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី សហព័ទ្ធ និងញាតិលោហិតខ្សែផ្ទាល់របស់ម្ចាស់បណ្តាំ

-បើសារការីជាអ្នកធ្វើមតកសាសន៍ សហព័ទ្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី និងនិយោជិតរបស់សារការីនោះ។

**ទម្រង់នៃមតកសាសន៍ដែលមានកំណត់នៅក្នុងច្បាប់ មានដូចខាងក្រោម**

**✓មតកសាសន៍ដោយលិខិតយថាភូត (CC#1173)**

+ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំនៅចំពោះមុខសារការី

+វត្តមានរបស់សាក្សី យ៉ាងតិច ០២ នាក់ (ពីរ)

+ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់នូវខ្លឹមសារនៃមតកសាសន៍ ចំពោះសារការី

+សារការីត្រូវសរសេរអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំជាលាយលក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និងសាក្សីស្តាប់

+ដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវចំពោះខ្លឹមសារនៃមតកសាសន៍ ម្ចាស់បណ្តាំ និងសាក្សីត្រូវចុះហត្ថលេខា ហើយត្រូវបញ្ជាក់អំពីឈ្មោះ អាយុ និងលំនៅឋាន ប៉ុន្តែបើម្ចាស់បណ្តាំមិនចេះសរសេរអក្សរ ឬមិនអាចចុះហត្ថលេខាបាន សារការីអាចធ្វើជំនួស ដោយបញ្ជាក់អំពីហេតុនោះ

+សារការីត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។

**ប្រសិនបើទម្រង់នេះ មិនត្រូវបានគោរព ឬបំពេញនោះទេ មតកសាសន៍នោះ នឹងត្រូវចាត់ទុកជាមោឃៈ។**

**✓មតកសាសន៍ដោយលិខិតសម្ងាត់ (CC#1175)**

+ម្ចាស់បណ្តាំត្រូវចុះហត្ថលេខាលើលិខិតនោះ

+ម្ចាស់បណ្តាំដាក់លិខិតនោះ នៅក្នុងស្រោមបិទជិត ហើយចុះហត្ថលេខា ឬធ្វើសញ្ញាសំគាល់ ឬប្រើមធ្យោបាយផ្សេងទៀត ដែលអាចនាំឱ្យវិនិច្ឆ័យអំពីការបើក ឬមិនបើកលិខិតនោះ

+ម្ចាស់បណ្តាំត្រូវដាក់លិខិតដែលបានបិទជិតនោះ នៅចំពោះមុខសារការីម្នាក់

និងសាក្សី ០២ (ពីរ) នាក់ ដោយធ្វើសេចក្តីថ្លែងការណ៍ថា លិខិតនេះជាមតកសាសន៍របស់ខ្លួន ហើយប្រសិនបើមានជនក្រៅពីសាមីខ្លួនសរសេរ ត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីឈ្មោះ និងលំនៅឋានរបស់ជននោះ

+សារការីត្រូវចុះកាលបរិច្ឆេទលើលិខិតមតកសាសន៍ដែលម្ចាស់បណ្តាំបានដាក់ និងសរសេរសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំ នៅលើលិខិតដែលបានបិទជិតនោះ ហើយត្រូវចុះហត្ថលេខានៅលើលិខិតនោះ ជាមួយម្ចាស់បណ្តាំ និងសាក្សី។

**ប្រសិនបើទម្រង់នេះ មិនត្រូវបានគោរព ឬបំពេញនោះទេ មតកសាសន៍នោះ នឹងត្រូវចាត់ទុកជាមោឃៈ។**

**✓មតកសាសន៍ដោយលិខិតឯកជន (CC#1174)**

+ម្ចាស់បណ្តាំសរសេរខ្លឹមសារនៃមតកសាន៍ទាំងអស់ និងចុះកាលបរិច្ឆេទដោយខ្លួនឯង ហើយចុះហត្ថលេខាលើលិខិតនោះ។ ផ្ទុយទៅវិញ បើមតកសាសន៍ ត្រូវបានសរសេរដោយអ្នកដទៃ ឬប្រើម៉ាស៊ីន ដូចជា កុំព្យូទ័រ ជាអាទិ៍ ត្រូវចាត់ទុកជាមោឃៈ

+ការបន្ថែម ការលុប ឬការកែប្រែផ្សេងៗ នៅក្នុងមតកសាសន៍ ពុំមានអានុភាព បើម្ចាស់បណ្តាំមិនបានសរសេរបន្ថែមនូវហេតុនោះ និងត្រូវចុះហត្ថលេខា។

**ប្រសិនបើទម្រង់នេះ មិនត្រូវបានគោរព ឬបំពេញនោះទេ មតកសាសន៍នោះ នឹងត្រូវចាត់ទុកជាមោឃៈ។**

មួយវិញទៀតទម្រង់មតកសាសន៍ អាចមានស្ថានភាពពិសេសមួយចំនួន ដូចជា ៖

**✓មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ (CC#1176)**

+ជននៅក្រោមអាណាព្យាបាលទូទៅ អាចធ្វើមតកសាសន៍បាន នៅពេលខ្លួនសះស្បើយមួយរយៈឡើងវិញនូវសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ត្រូវមានវត្តមានវេជ្ជបណ្ឌិតយ៉ាងតិច ០២ (ពីរ) រូប

+វេជ្ជបណ្ឌិតដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ ត្រូវសរសេរបញ្ជាក់បន្ថែមនៅលើលិខិតនោះថា នៅពេលដែលម្ចាស់បណ្តាំបានធ្វើមតកសាសន៍ ម្ចាស់បណ្តាំ ពុំបានស្ថិតនៅក្នុងស្ថានភាពខ្វះសមត្ថភាពនៅក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃ

សកម្មភាពរបស់ខ្លួន ដោយសារវិបត្តិស្មារតីនោះទេ បន្ទាប់មកចុះហត្ថលេខា ដោយបញ្ជាក់ថាខ្លួនជាវេជ្ជបណ្ឌិត។

**✓មតកសាសន៍របស់ជនដែលកំពុងជួបគ្រោះថ្នាក់ដល់អាយុជីវិត(CC#1177)**

+ម្ចាស់បណ្តាំកំពុងជួបគ្រោះថ្នាក់ដល់អាយុជីវិតដោយសារជម្ងឺ ឬហេតុផ្សេងៗ មានបំណងធ្វើមតកសាសន៍ មតកសាសន៍នោះអាចធ្វើបាន បើមានវត្តមានសាក្សីយ៉ាងតិច ០៣ (បី) នាក់ ហើយបានប្រកាសអំពីខ្លឹមសារនៃមតកសាសន៍នោះដោយផ្ទាល់មាត់ ចំពោះជនម្នាក់ក្នុងចំណោមសាក្សីទាំងបីនោះ។ នៅក្នុងករណីនេះ ជនដែលទទួលបានការប្រកាស ត្រូវសរសេរជាលាយលក្ខណ៍អក្សរនូវខ្លឹមសារនោះ អានឱ្យអ្នកដទៃ ស្តាប់ ឬមើល ហើយសាក្សីនីមួយៗត្រូវចុះហត្ថលេខាលើលិខិតនោះ

+សាក្សីណាម្នាក់ ឬបុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធ ត្រូវដាក់ពាក្យសុំទៅតុលាការ នៅក្នុងអំឡុងពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានធ្វើមតកសាសន៍នោះ ដើម្បីអាចបញ្ជាក់បានអំពីភាពត្រឹមត្រូវ

+តុលាការ ត្រូវធ្វើការបញ្ជាក់មតកសាសន៍នោះ បើយល់ឃើញថាមតកសាសន៍នោះ ចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ។

**✓មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង (CC#1178)**

+ម្ចាស់បណ្តាំដែលត្រូវជាប់ឃុំឃាំងដោយសារសេចក្តីសម្រេចរបស់តុលាការ អាចធ្វើលិខិតមតកសាសន៍បាន ដោយមានវត្តមាននគរបាល ឬមន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ និងសាក្សីយ៉ាងតិច ០២ នាក់ (ពីរ)

+បើម្ចាស់បណ្តាំនៅក្នុងនាវា ឬយន្តហោះ អាចធ្វើមតកសាន៍បាន តម្រូវឲ្យមានវត្តមានមេបញ្ជាការ ឬបរិបាលនាវា ឬបុគ្គលិកម្នាក់ និងសាក្សីយ៉ាងតិច ០២ នាក់ (ពីរ)

+អាចធ្វើមតកសាសន៍ដោយផ្ទាល់មាត់

+នគរបាល ឬមន្ត្រីនៃមន្ទីរឃុំឃាំង ជាអាទ៍ ត្រូវបានបកស្រាយថា ជាសារការី

+មតកសាន៍នេះ ពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំបន្តនៅរស់ ក្នុងអំឡុងពេល ០៦ (ប្រាំមួយ ខែ (គិតចាប់ពីពេលដែលខ្លួនត្រូវបានដោះលែង។

**✓មតកសាសន៍នៃជនដែលមិនអាចនិយាយបាន ជាអាទិ៍ (CC#1179)**

+ជនដែលមិនអាចនិយាយបាន អាចធ្វើមតកសាសន៍បាន ដោយម្ចាស់បណ្តាំធ្វើសេចក្តីថ្លែងការណ៍អំពីខ្លឹមសារនៃមតកសាសន៍ តាមការបកប្រែរបស់អ្នកបកប្រែ ឬសរសេរដោយដៃផ្ទាល់ខ្លួន នៅចំពោះសារការី ឬសាក្សី

+សារការី ឬបុគ្គលផ្សេងទៀត ត្រូវអានឱ្យម្ចាស់បណ្តាំស្តាប់ ឬសាក្សីនូវខ្លឹមសារនៃមតកសាសន៍ ក្រោយពេលសរសេរជាលាយលក្ខណ៍អក្សរអំពីខ្លឹមសារនោះ ហើយបើម្ចាស់បណ្តាំថ្លង់ ត្រូវអានឱ្យស្តាប់ ដោយមានការបកប្រែពីអ្នកបកប្រែ ទៅឱ្យម្ចាស់បណ្តាំ ឬសាក្សី

+សារការី ឬបុគ្គលផ្សេងទៀត ត្រូវសរសេរអំពីហេតុនោះ នៅក្នុងមតកសាសន៍

**✓មតកសាសន៍របស់បុគ្គលមានសញ្ជាតិខ្មែរដែលរស់នៅបរទេស (CC#1181)**

បុគ្គលមានសញ្ជាតិខ្មែរដែលរស់នៅបរទេស អាចធ្វើមតកសាសន៍ដោយលិខិតយថាភូត ឬលិខិតសម្ងាត់ នៅទីកន្លែងដែលមានកុងស៊ុល ឬទូតនៃប្រទេសកម្ពុជាប្រចាំនៅ ដោយកុងស៊ុល ឬទូតនោះ ត្រូវអនុវត្តតួនាទីជាសារការី។

**កំណត់សំគាល់ ៖** ក្នុងករណីដែលសារការី និងសាក្សីត្រូវចុះហត្ថលេខា សារការី និងសាក្សីអាចសរសេរឈ្មោះ ហើយអាចផ្តិតមេដៃជំនួសឱ្យការចុះហត្ថលេខាបាន (CC#1180)។

**៩.ខ្លឹមសារនៃមតកសាសន៍**

ខ្លឹមសារនៃមតកសាសន៍ ជាចំណុចសារវន្តត្រូវដាក់បញ្ចូលនៅក្នុងលិខិតមតកសាសន៍ ឬជាចរិករបស់លិខិតមតកសាសន៍ ដែលអាចឆ្លុះបញ្ចាំងអំពីឆន្ទៈរបស់មតកជន ហេតុនេះ ច្បាប់បានកំណត់នូវចំណុចជាសារវន្តទាំងនោះ ដូចខាងក្រោម ៖

**✓ការកំណត់ចំណែកមត៌ក(CC#1182)**

មតកជនអាចកំណត់ចំណែកមត៌ករបស់សហសន្តតិជនតាមមតកសាសន៍បាន ទោះបីជាផ្ទុយនឹងបញ្ញត្តិស្តីពីផលប្រយោជន៍ពិសេស ក៏ដោយ លើកលែងតែការកំណត់ចំណែកមត៌កនោះបំពានភាគបម្រុង។ ផ្ទុយទៅវិញ បើមតកជនបានកំណត់ចំណែកមត៌ក ចំពោះសន្តតិជនតែម្នាក់ ឬច្រើននាក់ ក្នុងចំណោមសហសន្តតិជនទាំងអស់ ចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវធ្វើឡើងតាមគោលការណ៍នៃការសម្រួលចំណែកមត៌ក ហើយបើបំពានភាគ

បម្រុង ត្រូវកាត់បន្ថយដើម្បីបង្គ្រាប់ភាគបម្រុង។

ឧទាហរណ៍ ៖ មតកជន បានបន្សល់ទុកនូវកូន ០៣នាក់ (A-B-C) និងទ្រព្យចំនួន ៩.០០០ កាលនៅរស់បានឲ្យកូន A ចំនួន ៥.០០០ និងនៅក្នុងខ្លឹមសារនៃមតកសាសន៍គឺឲ្យកូន B ចំនួន ៨.០០០ ហើយចំណែកដែលនៅសល់ឲ្យទៅកូនដទៃទៀត។

**✓ការកំណត់វិធីបែងចែក (CC#1183)**

មតកជនអាចកំណត់នូវវិធីបែងចែកតាមមតកសាសន៍ ឬប្រគល់អាណត្តិឱ្យតតិយជនកំណត់ ឬអាចហាមឃាត់មិនឱ្យបែងចែក នៅក្នុងអំឡុងពេល មិនលើសពី ០៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលសន្តតិកម្មចាប់ផ្តើម។

ឧទាហរណ៍ ៖ មតកជន បានបន្សល់ទុកនូវកូន ០៣នាក់ (A-B-C) ដោយនៅក្នុងមតកសាសន៍ បានកំណត់ជាក់លាក់អំពីវត្ថុដែលជាចំណែកមតិករបស់កូននីមួយៗ ដោយនៅក្នុងមតកសាសន៍នោះបានបញ្ជាក់ថា A ជាអ្នកប្រតិបត្តិមតកសាសន៍ (កូនច្បង) និងគ្រប់គ្រងទ្រព្យសម្បត្តិនេះ រហូតដល់ប្អូនៗមាននីតិភាព ទើបធ្វើការបែងចែក ដោយដីបានទៅ B ផ្ទះបានទៅ C ហើយទ្រព្យដទៃទៀតបានទៅ A។ ម្ចាស់ទ្រព្យបានទទួលមរណភាពនៅឆ្នាំ ២០១៥ ហេតុនេះទោះបីជាសន្តិកម្មបង្កើតអានុភាពក៏ដោយ ក៏មិនអាចអនុវត្តបាននោះទេ ត្រូវរងចាំដល់ឆ្នាំ ២០២០ ទើបអាចអនុវត្តបាន។

**✓អនុប្បទាន (CC#1184&CC#1185)**

មតកជនអាចធ្វើអនុប្បទានទ្រព្យសម្បត្តិទាំងអស់ ឬមួយផ្នែក ឬប្រទានកម្ម អច្ច័យទានតាមមតកសាសន៍ ឱ្យទៅជនដែលត្រូវបានសន្មតថាជាសន្តតិជន ឬតតិយជន។ មួយវិញទៀតបើមតកជនបានធ្វើមតកសាសន៍ ដែលមានអត្ថន័យជាកាធ្វើអនុប្បទាននូវទ្រព្យជាក់លាក់តែមួយ ឬច្រើនឱ្យទៅសហសន្តតិជនតែម្នាក់ ឬច្រើននាក់ មតកសាសន៍នោះ ត្រូវបានសន្មតថា ***<u>ជាការកំណត់នូវវិធីបែងចែកមតិក</u>*** លើកលែងតែមតកសាសន៍នោះ មានអត្ថន័យជា អច្ច័យទានច្បាស់លាស់ ដូចជា អច្ច័យទានភ្ជាប់បន្ទុក ជាអាទិ៍ និងបើតម្លៃនៃទ្រព្យដែលបានកំណត់នោះមានចំនួនលើសចំណែកមតិករបស់សន្តតិជន ត្រូវសន្មតថា ***<u>ជាកំណត់នូវចំណែកមតិក</u>***។ លើសពីនេះទៅទៀត ប្រសិនបើមតកជនបានធ្វើមតកសាសន៍ ចំពោះទ្រព្យតែមួយភាគនៅក្នុង

ចំណែកមតិក បើតម្លៃនៃទ្រព្យនោះ មានចំនួនតិចជាងចំណែកមតិកដែលសន្តតិជននោះត្រូវទទួល ត្រូវសន្មតថា ***ជាការកំណត់វិធីបែងចែកមតិក*** សម្រាប់សន្តតិជននោះ លើកលែងតែ មានការកំណត់ផ្សេងនៅក្នុងមតកសាសន៍។

**✓ការកំណត់អ្នកប្រតិបត្តិមតកសាសន៍(CC#1186)**

ម្ចាស់បណ្តាំអាចកំណត់អ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬច្រើននាក់ ឬអាចប្រគល់អាណត្តិឱ្យតតិយជន កំណត់អ្នកប្រតិបត្តិមតកសាសន៍ បានផងដែរ។

**✓ចំណុចផ្សេងៗ (CC#1187)**

ក្រៅពីចំណុចខាងលើ ដែលជាចំណុចនៃចរិកមតកសាសន៍ ម្ចាស់បណ្តាំអាចកំណត់នូវបញ្ញត្តិដែលជាលក្ខខណ្ឌផ្សេងៗ អាចនាំឱ្យមានសុខដុមរមនាដល់ក្រុមគ្រួសារ ដូចជា កូនៗត្រូវសាមគ្គីគ្នា ស្រលាញ់គ្នា ឲ្យតម្លៃគ្នាទៅវិញទៅមក មិនត្រូវយកទ្រព្យចម្បងពេកនោះទេ ជាអាទិ៍ដែលជាខ្លឹមសារពាក់ព័ន្ធនឹងសីលធម៌។

**៥.ការលុបចោលមតកសាសន៍**

ម្ចាស់បណ្តាំអាចលុបចោលមតកសាសន៍មួយភាគ ឬ ទាំងមូលបាន និងនៅពេលណាក៏បាន ឬទីណាក៏បាន មានន័យថា ចន្លោះពេលដែលបានធ្វើមតកសាសន៍ រហូតដល់មុនពេលម្ចាស់បណ្តាំទទួលមរណភាព។ មួយវិញទៀត ច្បាប់ទទួលស្គាល់ការលុបចោលមតកសាសន៍តាមទម្រង់ ០៣ យ៉ាង គឺ**ទី ១** ការលុបចោលដោយទម្រង់នៃមតកសាសន៍ **ទី ២** ការលុបចោលដោយការចាត់ចែងនាពេលនៅរស់ និង**ទី៣** ការលុបចោលដោយសារការបដិសេធលិខិតមតកសាសន៍។

**ទី១** ការលុបចោលដោយទម្រង់នៃមតកសាសន៍ ៖ ម្ចាស់បណ្តាំអាចលុបចោលមតកសាសន៍មួយភាគ ឬទាំងមូលតាមទម្រង់នៃមតកសាសន៍។ មានន័យថា បើមតកសាសន៍ដែលបានធ្វើក្រោយនេះមានភាពផ្ទុយគ្នានឹងមតកសាសន៍ដែលបានធ្វើមុន ត្រូវចាត់ទុកថាមតកសាសន៍ដែលធ្វើក្រោយនេះ លុបចោលមតកសាសន៍ដែលបានធ្វើមុន (កាលបរិច្ឆេទ)។

**ទី២** ការលុបចោលដោយការចាត់ចែងនាពេលនៅរស់ ៖ បើម្ចាស់បណ្តាំធ្វើអនុប្បទាន ឬធ្វើសកម្មភាពផ្សេងៗទៀតនាពេលនៅរស់ ត្រូវចាត់ទុកថា ម្ចាស់បណ្តាំបានលុបចោលមតក

សាសន៍ ចំពោះផ្នែកដែលផ្ទុយនឹងអនុប្បទាន ឬសកម្មភាពផ្សេងនោះ។ មានន័យថា តាមមតកសាសន៍ ចលនវត្ថុជាក់លាក់មួយត្រូវក្លាយជាអច្ច័យទានសម្រាប់កូន "ក" ប៉ុន្តែ កាលនៅរស់មតកជន បានធ្វើប្រទានកម្មនូវចលនវត្ថុជាក់លាក់នោះឱ្យទៅកូន "ខ" ហេតុនេះ មតកជន បានលុបចោលអច្ច័យទាន ដែលជាផ្នែកមួយនៃមតកសាសន៍។

**ទី៣** ការលុបចោលដោយការបដិសេធលិខិតមតកសាសន៍ ៖ បើម្ចាស់បណ្តាំបានបំផ្លាញច្បាប់ដើមនៃមតកសាសន៍ ឬវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍ ដោយចេតនា ត្រូវចាត់ទុកថាបានលុបចោលមតកសាសន៍ មានន័យថា លិខិតមតកសាសន៍ ជាភស្តុតាងដែលបង្ហាញពីឆន្ទៈរបស់មតកជន ហេតុនេះបើមតកជនបានបំផ្លាញ ត្រូវចាត់ទុកថា សាមីខ្លួនលុបចោលមតកសាសន៍ ឬនៅក្នុងខ្លឹមសារនៃមតកសាសន៍បានប្រគល់ប្រាក់នៅធនាគារឲ្យទៅកូន A ប៉ុន្តែកាលនៅរស់ម្ចាស់បណ្តាំបានចាយលុយនោះអស់ ជាអាទិ៍។

**βកំណត់សំគាល់**

✓ការលុបចោលអច្ច័យទានភ្ជាប់បន្ទុក (CC#1193) ៖ ប្រសិនបើ អច្ច័យលាភី មិនបានបំពេញករណីយកិច្ចដែលម្ចាស់បណ្តាំឱ្យធ្វើ ដែលជាថ្នូរនៃអច្ច័យទានទេនោះ អ្នកប្រតិបត្តិមតកសាសន៍ ឬបើគ្មានទេនោះ សន្តតិជនអាចដាស់តឿនឱ្យអច្ច័យលាភីនោះ អនុវត្តករណីយកិច្ចរបស់ខ្លួននៅក្នុងអំឡុងពេលសមរម្យ ហើយបើអច្ច័យលាភីនោះមិនបាន អនុវត្តនូវករណីយកិច្ចរបស់ខ្លួន នៅក្នុងអំឡុងពេលដែលបានកំណត់ទេ អ្នកប្រតិបត្តិមតកសាសន៍ ឬសន្តតិជននោះអាចទាមទារទៅតុលាការឱ្យលុបចោលអច្ច័យទាននោះបាន។

✓ការបោះបង់សិទ្ធិលុបចោលមតកសាសន៍ (CC#1192) ៖ **ម្ចាស់បណ្តាំមិនអាចបោះបង់សិទ្ធិលុបចោលមតកសាសន៍បានឡើយ។**

**៦. អានុភាពនៃមតកសាសន៍**

✓**កំណើតអានុភាព**៖ ជាគោលការណ៍មតកសាសន៍មានអានុភាពនៅពេលម្ចាស់បណ្តាំបានទទួលមរណភាព ហើយមតកសាសន៍ជាឆន្ទៈរបស់ម្ចាស់បណ្តាំក្នុងការសម្រេចនូវកម្មសិទ្ធិទ្រព្យសម្បត្តិ ក្រោយពេលដែល ខ្លួនបានទទួលមរណភាព ហេតុនេះប្រសិនបើ មតកសាសន៍នោះមានលក្ខខណ្ឌបង្អង់ លុះត្រាតែលក្ខខណ្ឌនោះត្រូវ បានបំពេញ ទើបមតកសាសន៍

នោះមានអានុភាព។

ឧទាហរណ៍ ៖ អច្ច័យលាភី បានទទួលអច្ច័យទានភ្ជាប់បន្ទុក ដែលមានខ្លឹមសារថា អច្ច័យទាននេះអាចត្រូវបានប្រគល់ លុះត្រាតែអច្ច័យលាភីរៀបអាពាហ៍ពិពាហ៍ ឬនៅក្នុងមតកសាសន៍បានបញ្ញត្តិថា សហព័ទ្ធដែលទទួលចំណែកមតិក មិនត្រូវរៀបការឡើយនៅក្នុងអំឡុងពេល ០៥ (ប្រាំ) ឆ្នាំ ទើបអាចទទួលមតិករបស់ខ្លួនបាន។

✓**អានុភាពនៃការកំណត់ចំណែកមតិក** ៖ មតកជនបានកំណត់ចំណែកមតិក ឬវិធីបែងចែកមតិក ដោយធ្វើអនុប្បទាននូវទ្រព្យជាក់លាក់មួយ ឬច្រើន ទៅឱ្យសន្តតិជនម្នាក់ ឬច្រើន តាមរយៈមតកសាសន៍ ទ្រព្យនោះ នឹងធ្លាក់ទៅសន្តតិជន ដែលនឹងត្រូវទទួលទ្រព្យនោះដោយស្វ័យប្រវត្តិ នៅពេលមតកសាសន៍បង្កើតអានុភាព។ នៅក្នុងករណីនេះ មានការកំណត់នូវវិធីបែងចែកមតិក តាមមតកសាសន៍ ហេតុនេះ មតិកត្រូវបែងចែកតាមវិធី ដែលបានកំណត់នោះ ដោយមិនចាំបាច់ឆ្លងកាត់ការពិភាក្សាដោយសហសន្តតិជនឡើយ។ មួយវិញទៀត បើមតកសាសន៍នោះភ្ជាប់ជាមួយនឹងលក្ខខណ្ឌបង្អង់ លុះត្រាតែលក្ខខណ្ឌនោះត្រូវបានបំពេញ ទើបសន្តតិជន ជាអាទិ៍ អាចទទួលបន្តនូវទ្រព្យទាំងនោះ ដោយចាត់ទុកថា មានអានុភាពប្រតិសកម្ម គិតចាប់ពីថ្ងៃដែលម្ចាស់បណ្តាំនោះបានស្លាប់។

✓**មរណភាពរបស់ជនដែលត្រូវបានសន្មតថាជាសន្តតិជន** ៖ ក្នុងករណី ជនដែលត្រូវបានសន្មតថាជាសន្តតិជន បានទទួលមរណភាពមុនពេលចាប់ផ្តើមសន្តតិកម្ម អានុភាពនៃការកំណត់ចណែកមតិករបស់សន្តតិជន ឬការកំណត់នូវវិធីបែងចែកមតិក តាមរយៈមតកសាសន៍ នឹងមានអានុភាពចំពោះសនត្តិជនជំនួស លើកលែងតែ សន្តតិជនបោះបង់សន្តតិកម្ម ឬមតកជនបានបង្ហាញឆន្ទៈផ្សេងនៅក្នុងមតកសាសន៍ ឬគ្មានសន្តតិជនជំនួស។

✓**ការកម្រិតនូវមតកសាសន៍ចំពោះអ្នកអាណាព្យាបាលទូទៅ** ៖ យោងតាមមាត្រា ១១៧៦ នៃក្រមរដ្ឋប្បវេណី ជននៅក្រោមអាណាព្យាបាលទូទៅ អាចធ្វើមតកសាសន៍បាន ប៉ុន្តែជននៅក្រោមអាណាព្យាបាលទូទៅ មិនអាចធ្វើមតកសាសន៍ ផ្តល់ប្រយោជន៍ឱ្យទៅអ្នកអាណាព្យាបាលទូទៅបានទេ ប្រសិនបើមានមតកសាសន៍ មតកសាសន៍នោះនឹងត្រូវចាត់ទុកជាមោឃៈ លើកលែងតែ អ្នកអាណាព្យាបាលទូទៅនោះ ជាញាតិលោហិតខ្សែផ្ទាល់ ឬសហព័ទ្ធ ឬ

បងប្អូនបង្កើត ពីព្រោះជាទូទៅ ជននៅក្រោមអាណាព្យាបាលទូទៅ (ម្ចាស់បណ្តាំ) តែងតែមានឆន្ទៈ ឲ្យមត៌កទៅជនទាំងនោះ ហេតុនេះមតកសាសន៍នោះត្រូវចាត់ទុកថាមានសុពលភាព។

✓**សិទ្ធិទទួលទ្រព្យសម្បត្តិក្នុងករណីដែលអច្ច័យទានត្រូវបានមោឃភាព** ៖ ក្នុងករណីដែលអច្ច័យលាភី ជាអភព្វបុគ្គល ឬទទួលមរណភាព ឬបោះបង់អច្ច័យទាន ឬហេតុផ្សេងទៀត អច្ច័យទាននឹងមិនបង្កើតអានុភាពឡើយ ហើយទ្រព្យដែលអច្ច័យលាភីត្រូវទទួលនោះត្រូវធ្លាក់ទៅសន្តតិជននៃមតកជន លើកលែងតែ មតកជន បានបង្ហាញឆន្ទៈផ្សេងនៅក្នុងមតកសាសន៍។

ឧទាហរណ៍១ ៖ មតកជន បានសរសេរមតកសាសន៍ដែលមានខ្លឹមសារថា ធ្វើអច្ច័យទានចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ឲ្យទៅ ក្មួយ ប្រសិនបើក្មួយនោះបានស្លាប់ មុនពេលមតកសាសន៍បង្កើតអានុភាព នាំឲ្យទ្រព្យនោះធ្លាក់ទៅសន្តតិជនរបស់ម្ចាស់បណ្តាំ។

ឧទាហរណ៍២ ៖ មតកជន បានសរសេរមតកសាសន៍ដែលមានខ្លឹមសារថា ធ្វើអច្ច័យទានចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ឲ្យទៅ ក្មួយ ប្រសិនបើក្មួយនោះបានស្លាប់ មុនពេលមតកសាសន៍បង្កើតអានុភាព ទ្រព្យសម្បត្តិទាំងអស់នោះ ត្រូវធ្វើអច្ច័យទានឱ្យទៅបច្ចាញាតិផ្ទាល់របស់ក្មួយចុះ ហេតុនេះ ត្រូវធ្វើតាម ឆន្ទៈរបស់មតកជន។

**៧.ការប្រតិបត្តិមតកសាសន៍**

✓**ការបញ្ជាក់ និងការបើកលិខិតមតកសាសន៍** ៖ មតកសាសន៍ដែលធ្វើឡើងក្រៅពីទម្រង់នៃលិខិតយថាភូត ចាំបាច់ត្រូវធ្វើការពិនិត្យ និងបញ្ជាក់។ ការពិនិត្យ និងបញ្ជាក់លិខិតមតកសាសន៍ ត្រូវធ្វើឡើងដើម្បីឱ្យជនដែលមានផលប្រយោជន៍ពាក់ព័ន្ធបានដឹងឮ និងដើម្បីកំណត់នូវខ្លឹមសារនៃមតកសាសន៍នោះ ហេតុនេះ អ្នកថែរក្សា គ្រប់គ្រងលិខិតមតកសាសន៍ត្រូវដាក់ពាក្យសុំឱ្យធ្វើការពិនិត្យបញ្ជាក់ ទៅតុលាការ នៅពេលចាប់ផ្តើមសន្តតិកម្ម និងបើបានរកឃើញលិខិតមតកសាសន៍ ក្រោយមរណភាពរបស់មតកជន ត្រូវដាក់ពាក្យសុំទៅតុលាការគ្មានការយឺតយ៉ាវ។ មួយវិញទៀតចំពោះលិខិតមតកសាសន៍បិទដោយប្រថាប់ត្រា ត្រូវបើកនៅក្នុងនីតិវិធីតុលាការ ដើម្បីកុំឲ្យមានការកែប្រែ។ បើជនណាបើកលិខិតមតកសាសន៍ប្រភេទនេះនៅក្រៅតុលាការ នឹងទទួលរងពិន័យស៊ីវិលមិនលើសពី ១.០០០.០០០ (មួយលាន) រៀល ប៉ុន្តែ

លិខិតមតកសាសន៍មិនត្រូវបានចាត់ទុកជាមោឃៈដោយសារមូលហេតុនេះ នោះទេ។

✓**ការកំណត់អ្នកប្រតិបត្តិមតកសាសន៍** ៖ ក្នុងករណីដែលម្ចាស់បណ្តាំបានប្រគល់អាណត្តិឱ្យតតិយជន កំណត់អ្នកប្រតិបត្តិមតកសាសន៍ តាមមតកសាសន៍ ជនដែលបានទទួលអាណត្តិនោះ ត្រូវកំណត់អ្នកប្រតិបត្តិមតកសាសន៍ និងជូនដំណឹងទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ។ ប្រសិនបើនៅក្នុងមតកសាសន៍មិនបានហាមឃាត់ជនដែលទទួលអាណត្តិក្នុងការអនុវត្តតួនាទីជាអ្នកប្រតិបត្តិមតកសាសន៍នោះទេ អ្នកទទួលអាណត្តិអាចតែងតាំងខ្លួនឯងជាអ្នកប្រតិបត្តិមតកសាសន៍។ ផ្ទុយទៅវិញ បើជនដែលទទួលអាណត្តិ មានបំណងលាឈប់ពីអាណត្តិ ជននោះត្រូវជូនដំណឹងអំពីហេតុនេះទៅសន្តតិជនដោយគ្មានការយឺតយ៉ាវ ប៉ុន្តែ ក្នុងករណីដែលអ្នកទទួលអាណត្តិមិនបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ ឬមិនបានបង្ហាញឆន្ទៈលាឈប់ពីអាណត្តិ នីតិវិធីនៃការដាស់តឿន នឹងត្រូវបានអនុវត្តចំពោះជននោះ។

✓**ការដាស់តឿនឱ្យអ្នកប្រតិបត្តិមតកសាន៍កាន់មុខងារ** ៖ សន្តតិជន ឬជនដែលមានប្រយោជន៍ពាក់ព័ន្ធ អាចកំណត់អំឡុងពេលសមរម្យ និងធ្វើការដាស់តឿនចំពោះជនដែលត្រូវបានកំណត់ថាជាអ្នកប្រតិបត្តិមតកសាសន៍ ឱ្យធ្វើការឆ្លើយតបនៅក្នុងអំឡុងពេលនោះ អំពីការយល់ព្រម ឬមិនយល់ព្រម ហើយបើអ្នកប្រតិបត្តិ មតកសាសន៍នោះ មិនឆ្លើយតបនៅក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថាលាឈប់ពីការងារ។ មួយវិញទៀត ចំពោះជនដែលត្រូវបានប្រគល់អាណត្តិឱ្យកំណត់អ្នកប្រតិបត្តិមតកសាសន៍ ពុំបានកំណត់អ្នកប្រតិបត្តិមតកសាសន៍នៅក្នុងអំឡុងពេលដាស់តឿននេះទេ ត្រូវចាត់ទុកថា លាឈប់ពីអាណត្តិនោះ។

✓**ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍**៖ក្នុងករណីគ្មានអ្នកប្រតិបត្តិមតកសាសន៍ ឬបាត់បង់អ្នកប្រតិបត្តិមតកសាសន៍ តុលាការអាចជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ តាមពាក្យសុំរបស់សន្តតិជន ឬអ្នកមានប្រយោជន៍ពាក់ព័ន្ធ។ ជាគោលការណ៍ អ្នកប្រតិបត្តិមតកសាសន៍ជាអ្នកធ្វើសកម្មភាពគតិយុត្ត ក្រោយមតកសាសន៍មានអានុភាព ហេតុនេះ បុគ្គលដែលមិនអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍ ត្រូវបានច្បាប់កំណត់ដូចជា ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភ អនីតិជន និងជនធនក្ស័យ (CC#1217)។

✓**មុខងារ និងសិទ្ធិអំណាចរបស់អ្នកប្រតិបត្តិមតកសាសន៍ (ជ្រើសតាំងបន្ត)**៖ អ្នក

ប្រតិបត្តិមតកសាសន៍ មានសិទ្ធិ និងករណីយកិច្ចក្នុងការគ្រប់គ្រងមតិក និងធ្វើសកម្មភាពចាំបាច់ដើម្បីប្រតិបត្តិមតកសាសន៍ មានន័យថា អ្នកប្រតិបត្តិមតកសាសន៍ អាចសងកាតព្វកិច្ចនៃមតិក ឬម្ចាស់បំណុលរបស់មតកជន អាចទាមទារឱ្យអ្នកប្រតិបត្តិមតកសាសន៍នោះ សងបំណុលនោះបាន ឬប្រសិនបើនៅក្នុងមតកសាសន៍មានអច្ច័យទាន អច្ច័យលាភី អាចទាមទារឱ្យអ្នកប្រតិបត្តិមតកសាសន៍ អនុវត្តអច្ច័យទាននោះ ផងដែរ។

មួយវិញទៀតអ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ដោយមានវត្តមានរបស់សន្តតិជន ហើយប្រគល់បញ្ជីនោះទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ និងនៅពេលដែលមានវត្តមានរបស់អ្នកប្រតិបត្តិមតកសាសន៍ សន្តតិជនពុំអាចចាត់ចែងមតិក ឬធ្វើសកម្មភាពរារាំងដល់ការប្រតិបត្តិមតកសាសន៍បានឡើយ។ អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើសកម្មភាពចំពោះមតិកដែលខ្លួនទទួលអាណត្តិ និងត្រូវមានអានុភាពចំពោះសន្តតិជន មានន័យថា បើអនុវត្ត (អ្នកតំណាងរបស់សន្តតិជន) សន្តតិជនបានបំពេញអច្ច័យទានដោយអ្នកប្រតិបត្តិមតកសាសន៍ នោះគេវាយតម្លៃថា សន្តតិជនបានបំពេញករណីយកិច្ចអច្ច័យទានដោយរាប់បញ្ចូលទាំងសកម្មភាពបណ្ដឹង ហេតុនេះបើមានបណ្ដឹង សន្តតិជនគឺជាតំណាង។

លើសពីនេះទៅទៀត បើគ្មានមូលហេតុដែលពុំអាចជៀសវាងបានទេ អ្នកប្រតិបត្តិមតកសាសន៍ ពុំអាចឱ្យតតិយជនអនុវត្តភារកិច្ចជំនួសខ្លួនឡើយ លើកលែងតែមតកជនបានបង្ហាញឆន្ទៈផ្សេងនៅក្នុងមតកសាសន៍។ បើតតិយជនអនុវត្តភារកិច្ចរបស់អ្នកប្រតិបត្តិមតកសាសន៍ អ្នកប្រតិបត្តិមតកសាសន៍នោះ ត្រូវទទួលខុសត្រូវចំពោះអច្ច័យលាភី និងសន្តតិជន ប្រសិនបើមានការខូចខាត (ការសងសំណងនៃការខូចខាត ជាអាទិ៍)។

✓**សហអ្នកប្រតិបត្តិមតកសាសន៍** ៖ ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍មានចំនួនច្រើននាក់ ការអនុវត្តត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្ដាល លើកលែងតែម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈផ្សេងនៅក្នុងមតកសាសន៍ ប៉ុន្តែអ្នកប្រតិបត្តិមតកសាសន៍ ក៏អាចធ្វើសកម្មភាពរក្សាទុក ផងដែរ។

✓**កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍** ៖ អ្នកប្រតិបត្តិមតកសាសន៍ អាចទទួលកម្រៃដែលមានកំណត់នៅក្នុងមតកសាសន៍បាន បើនៅក្នុងមតកសាសន៍ ពុំបានកំណត់កម្រៃ

នោះទេ តុលាការត្រូវកំណត់ចំនួនកម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍ តាមពាក្យសុំរបស់អ្នកប្រតិបត្តិមតកសាសន៍ ដោយពិចារណា ភាពសមរម្យនៅក្នុងការបង់កម្រៃ ស្ថានភាពនៃមតិកទំនាក់ទំនងរវាងម្ចាស់បណ្តាំ និងអ្នកប្រតិបត្តិមតកសាសន៍ រាប់បញ្ចូលទាំងស្ថានភាពផ្សេងៗ។

✓**សោហ៊ុយនៃការប្រតិបត្តិមតកសាសន៍** ៖ សោហ៊ុយពាក់ព័ន្ធនឹងការប្រតិបត្តិមតកសាសន៍ជាបន្ទុកនៃមតិក ប៉ុន្តែមិនអាចបន្ថយភាគបម្រុង ដោយសារបន្ទុកនេះទេ។ សោហ៊ុយដើម្បីប្រតិបត្តិមតកសាសន៍ មានដូចជា សោហ៊ុយចាំបាច់ដើម្បីធ្វើនីតិវិធីពិនិត្យបញ្ជាក់លិខិតមតកសាសន៍ សោហ៊ុយធ្វើបញ្ជីសារពើភ័ណ្ឌមតិក សោហ៊ុយគ្រប់គ្រងមតិក និងកម្រៃនៃអ្នកប្រតិបត្តិមតកសាសន៍ ជាអាទិ៍។ មួយវិញទៀត ការកាត់សោហ៊ុយប្រតិបត្តិមតកសាសន៍នេះមិនអាចបន្ថយភាគបម្រុងបានឡើយ។

✓**ការលាឈប់ និងការបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍** ៖ បើមានមូលហេតុត្រឹមត្រូវអ្នកប្រតិបត្តិអាចដាក់ពាក្យសុំលាឈប់ទៅតុលាការ មានន័យថា "មូលហេតុត្រឹមត្រូវ" គឺមានជម្ងឺ ឬទៅបំពេញបេសកម្មនៅឆ្ងាយរយៈពេលវែង ឬកាន់មុខងារថ្មីដែលមានភាពមមាញឹកខ្លាំង ជាអាទិ៍។ ផ្ទុយទៅវិញប្រសិនបើមាន មូលហេតុត្រឹមត្រូវ ជនដែលមានផលប្រយោជន៍ពាក់ព័ន្ធ (សន្តតិជន ឬអច្ច័យលាភី ជាអាទិ៍) អាចដាក់ពាក្យសុំទៅតុលាការ ឲ្យបញ្ឈប់តួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍បាន បើមានមូលហេតុត្រឹមត្រូវ។ មូលហេតុត្រឹមត្រូវដូចជា ភាពខ្ជិលច្រអូសក្នុងការបំពេញមុខងារ ឬបាត់ខ្លួន ឬមានជម្ងឺប្រចាំកាយ រយៈពេលវែង ជាអាទិ៍។

ꕥ**កំណត់សំគាល់** ៖ បញ្ញត្តិស្តីពីអាណត្តិ ត្រូវយកមកអនុវត្តចំពោះតួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍ លើកលែងតែ ចំណុចដែលមានលក្ខណៈផ្ទុយគ្នានឹងគោលការណ៍សន្តតិកម្ម (CC#1229)៕